២. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ម៉ែត្រ ពីអគារស្ថានីយ
៣. ត្រូវបំពាក់គន្លឹះអាសន្នរួម
៤. ត្រូវមានគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៥. ត្រូវមានស្លាកសញ្ញាបម្រាម ស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ និងផ្ទាំងព័ត៌មានស្តីពីនីតិវិធីការផ្ទេរប្រេងឥន្ធនៈ

៦. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ.០១៩៨.រថៈអបក.ណអ.........ចុះថ្ងៃទី.......៣១.........ខែ.....មីនា......ឆ្នាំ២០.១៧............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ..០១៩៨.រថៈអបក.ណអ ចុះថ្ងៃទី.....៣១...ខែ.......មីនា......ឆ្នាំ២០.១៧...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២២
រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ សែម

កន្លែងទទួល:
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -រដ្ឋបាលរាជធានីភ្នំពេញ
- -ដូចប្រការ១៣
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៣០០១៥៨ អបប៉ក.ប៉ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០៣០០១៥៨ អបប៉ក.លម ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាព សម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ របស់លោក **កូវ ឆូ**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូ ឆៃ ឆូ** ស្ថិតនៅភូមិរកាកោងជើង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម របស់លោក **កូវ ឆូ** (**ម្ចាស់ស្ថានីយ**)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. គួរពង្រីកក្បាលដីស្ថានីយឱ្យបានប្រវែងអប្បបរមា ២៥ម៉ែត្រ
២. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ
៣. មិនអនុញ្ញាតឱ្យបញ្ចូល និងចែកចាយប្រេងឥន្ធនៈ ដាក់ក្នុងបីដុងជ័រក្នុងបរិវេណស្ថានីយ
៤. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៥. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរម ២ម៉ែត្រ ពី របងព្រំដីស្ថានីយ
៦. មិនត្រូវបំពាក់វ៉ាន់បិទ បើកនៅជាប់នឹងតួបំពង់ខ្យល់ប្រេងឥន្ធនៈ
៧. ត្រូវមានរបាំងការពារបំពង់ខ្យល់ប្រេងឥន្ធនៈ

៨. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
៩. ត្រូវបំពាក់គន្លឹះអាសន្នរួម និងគន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ
១០. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ម៉ែត្រ
១១. ត្រូវមានគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
១២. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១៣. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១៤. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១៥. ត្រូវសង់របងជញ្ជាំងធ្វើពីវត្ថុធាតុមិនឆាបឆេះ និងកំពស់អប្បបរមា ៣ម៉ែត្រ បាំងជិតនៅព្រំដីស្ថានីយដែលនៅជាប់នឹងព្រំដីលំនៅដ្ឋាន។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ.០១០០.រ៩:អយក.ចអ..........ចុះថ្ងៃទី..៣១..............ខែ....មីនា.......ឆ្នាំ២០២២...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០១០០.រ៩:អយក.ចអ ចុះថ្ងៃទី....៣១......ខែ....មីនា.........ឆ្នាំ២០២២...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ចាម និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១៤រោច ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២២
រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ សែម

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ចាម
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០២២៦ រ៉ែ.អ/ចក.ថក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០២២៦ រ៉ែ.អ/បក.លអ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយល្បាយប្រេងនិង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់លោក **សន ថន**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា សន ថន** ស្ថិតនៅភូមិបែកអន្លូង ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម របស់លោក **សន ថន** (**ម្ចាស់ស្ថានីយ**)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោមក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. គួរពង្រីកក្បាលដីស្ថានីយឱ្យបានប្រវែងអប្បបរមា ២៥ម៉ែត្រ
២. មិនអនុញ្ញាតឱ្យដាក់អីវ៉ាន់ដោយគ្មានសណ្តាប់ធ្នាប់ក្នុងបរិវេណស្ថានីយ
៣. មិនអនុញ្ញាតឱ្យបញ្ចូល និងលក់ចែកចាយប្រេងឥន្ធនៈតាមប៊ីដុងជ័រក្នុងបរិវេណស្ថានីយ
៤. មិនអនុញ្ញាតឱ្យដាក់លក់សាំងដបក្នុងបរិវេណស្ថានីយ
៥. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ

៦. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ

៧. ត្រូវមានរបាំងការពារបំពង់ខ្យល់ប្រេងឥន្ធនៈ

៨. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រ ពី របងព្រំដីស្ថានីយ

៩. ត្រូវបំពាក់គន្លឹះអាសន្នរួម និងគន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ

១០. ត្រូវមានគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ

១១. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

១២. ត្រូវស្លាកសញ្ញាបម្រាម ស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ និងផ្ទាំងព័ត៌មាន ស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ

១៣. ត្រូវសង់របងជញ្ជាំង ធ្វើពីវត្ថុធាតុមិនឆាបឆេះ និងកំពស់អប្បបរមា ៣ម៉ែត្រ បាំងជិតនៅព្រំដីស្ថានីយដែលនៅជាប់នឹងព្រំដីលំនៅដ្ឋាន។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០២២៣.រ.៥អ.ប្រក.ហអ.........ចុះថ្ងៃទី..១១...............ខែមេសា........ឆ្នាំ២០២២...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០២២៣..រ.៥អ.ប្រក.ហអ ចុះថ្ងៃទី......១១.....ខែ.....មេសា.......ឆ្នាំ២០២២..នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តកំពង់ចាម និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ...១០កើត.ខែ...ចេត្រ....ឆ្នាំខាល..ចត្វាស័ក.ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១១...ខែ.មេសា..ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ សែម

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ចាម
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៧៣០ រ៉ែ.ថប.ប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០៧៣០ រ៉ែ.ថប.ប្រក.លអ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ របស់លោកស្រី **ឡាំ សុភ័ក្រ**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ភីធីធី** ស្ថិតនៅផ្លូវលេខ១០៥ កែងនឹងផ្លូវលេខ១០៧ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ របស់លោកស្រី **ឡាំ សុភ័ក្រ** (**ម្ចាស់ស្ថានីយ**)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ២ម៉ែត្រ ពី របងព្រំដីស្ថានីយ
២. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
៣. ត្រូវមានគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៤. ត្រូវសង់របងជញ្ជាំងធ្វើពីវត្ថុធាតុមិនឆាបឆេះ និងកំពស់អប្បបរមា ៣ម៉ែត្រ[illegible]ព្រំដីស្ថានីយដែលនៅជាប់នឹងព្រំដីលំនៅដ្ឋាន។

ប្រការ៥.--

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.--

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.--

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.--

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.--

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.--

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.--

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ.០២៣០១៥:អ.ប៉ក.ណអ............ចុះថ្ងៃទី...១៣..............ខែ....មេសា.....ឆ្នាំ២០២២...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.--

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០២៣០១៥:អ.ប៉ក.ណអ ចុះថ្ងៃទី.....១៣.....ខែ..មេសា..........ឆ្នាំ២០២២....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលរាជធានីភ្នំពេញ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ សែម

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៧៨ កយ.ប្រ.ក/២២

ប្រកាស

ស្តីពី

ការបែងចែកក្របខណ្ឌមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២០/១២០៤ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- បានឃើញអនុក្រឹត្យលេខ ១៧៣ អនក្រ.តត ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ
- បានឃើញប្រកាសលេខ ១០២ កយ.ប្រក/២០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងយុត្តិធម៌ ស្តីពីការបញ្ចូលក្របខណ្ឌមន្ត្រីរាជការ
- យោងតាមសំណើរបស់ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិកនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌

សម្រេច

ប្រការ១ .-

ត្រូវបានបែងចែកក្របខណ្ឌមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ ចំនួន **៤រូប** ឲ្យទៅបម្រើការងារនៅតាមអង្គភាពនានានៃទីស្តីការក្រសួងយុត្តិធម៌ និងនៅតាមអង្គភាពរដ្ឋបាលនានានៃសាលាជម្រះក្តី ដូចមានរាយនាមខាងក្រោម ៖

លរ	គោត្តនាម និងនាម	អត្តលេខ	ប្រភេទក្របខណ្ឌ	មុខតំណែង	កម្រិតជំនាញ
ក.ទីស្តីការក្រសួងយុត្តិធម៌ ក.១.នាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ					
១	លោក ចែម បញ្ញា	១៩៦០៥០០០៦៨	ខ.៣.១	មន្ត្រីក្រមការ	មន្ត្រីក្រមការ នៃសាលាភូមិន្ទរដ្ឋបាល
ក.២.នាយកដ្ឋានកិច្ចការបុគ្គលិក					
២	លោក ថៃលាង អេង	១៩៨១២០០០២៩	ខ.៣.១	មន្ត្រីក្រមការ	មន្ត្រីក្រមការ នៃសាលាភូមិន្ទរដ្ឋបាល
ក.៣.នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី					
៣	លោក អ៊ិន សុគា	១៩៨២១០០២៥៤	ក.៣.១	មន្ត្រីគ្រប់គ្រងរដ្ឋបាល	មន្ត្រីជាន់ខ្ពស់ ផ្នែក សេដ្ឋកិច្ច-ហិរញ្ញវត្ថុ នៃសាលាភូមិន្ទរដ្ឋបាល
ខ.អង្គភាពរដ្ឋបាលនៃសាលាជម្រះក្តី ខ.១.លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តតាកែវ					
៤	លោក ម៉ុន ភារៈ	១៩៦២១០០១៣១	ខ.៣.១	មន្ត្រីក្រមការ	មន្ត្រីក្រមការ នៃសាលាភូមិន្ទរដ្ឋបាល

ប្រការ២ .-

ប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់សាមីខ្លួន ត្រូវបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីបញ្ជីបើកប្រាក់របស់អង្គភាពដើម។

ប្រការ៣ .-

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កើត រិទ្ធ

កន្លែងទទួល ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ: ៧៥៨ ប្រ.ក.

ប្រកាស

ស្តីពី

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពប្រហាក់ប្រហែលក្រោមឱវាទ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៨ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក. ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក. ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក. ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៥៦ អនក្រ.បក. ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- បានឃើញប្រកាសរួមលេខ៧៩៦ សហវ.ប្រក. ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- យោងតាមការចាំបាច់របស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងកំណត់អំពីតួនាទីនិងភារកិច្ចរបស់ការិយាល័យនិងអង្គភាពប្រហាក់ប្រហែលទាំងអស់ដែលស្ថិតនៅក្រោមឱវាទសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

ជំពូកទី២
លេខាធិការដ្ឋាន

ប្រការ ២.-

លេខាធិការដ្ឋានមានការិយាល័យក្រោមឱវាទចំនួន៤ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាល

២. ការិយាល័យគណនេយ្យនិងគ្រប់គ្រងហិរញ្ញវត្ថុ

៣. ការិយាល័យធនធានមនុស្ស

៤. ការិយាល័យទំនាក់ទំនងជាតិ-អន្តរជាតិ និង ព័ត៌មាននិងផ្សព្វផ្សាយ។

ប្រការ ៣.- តួនាទីភារកិច្ចការិយាល័យនីមួយៗមានដូចតទៅ÷

១.ការិយាល័យរដ្ឋបាល

- រៀបចំផែនការសកម្មភាពនិងផែនការថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- រៀបចំតាក់តែងលិខិតនិងអនុវត្តគ្រប់កិច្ចការរដ្ឋបាលទូទៅ
- គ្រប់គ្រងចរន្តលិខិតចេញ-ចូលនិងឯកសារផ្សេងៗ
- ផ្គត់ផ្គង់សម្ភារការិយាល័យ ទព្វសម្ភារៈ ជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងបន្លាស់ផ្សេងៗ ដែលចាំបាច់សម្រាប់ដំណើរការរបស់លេខាធិការដ្ឋាន
- គ្រប់គ្រងនិងបែងចែកការងារបុគ្គលិក សន្តិសុខ សណ្តាប់ធ្នាប់អនាម័យ
- រៀបចំចាត់ចែងរាល់កម្មវិធីនានារបស់សាកលវិទ្យាល័យ
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ និងស្ថាប័ន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

២.ការិយាល័យគណនេយ្យនិងគ្រប់គ្រងហិរញ្ញវត្ថុ

- គ្រប់គ្រងការប្រមូលចំណូល ទូទាត់ចំណាយ ការងារទូទាត់ និងផ្គត់ផ្គង់និងតាមដាននៃការអនុវត្តថវិកា
- រៀបចំផែនការសកម្មភាពនិងផែនការថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- រៀបចំគម្រោងថវិកាចំណូល-ចំណាយប្រចាំឆ្នាំនិងផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិលរបស់សាកលវិទ្យាល័យ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- កាន់កាប់បញ្ជីគណនេយ្យនិងរក្សាទុកលិខិតយុត្តិការច្បាប់ដើម

- ជាជំនួយឱ្យគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការសហការរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់ស្ថាប័ន
- គ្រប់គ្រងគណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គ្រប់គ្រងនិងថែរក្សារាល់ឯកសារដែលគាំទ្ររាល់ការប្រតិបត្តិការថវិកាក្នុងថិរវេលាមួយកំណត់តាមច្បាប់ហិរញ្ញវត្ថុ និងសម្រាប់ដំណើរការសវនកម្មផ្ទៃក្នុងនិងសវនកម្មខាងក្រៅ
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ
- សហការរៀបចំគោលការណ៍កៀរគរចំណូល គោលការណ៍ចំណាយ និងគោលការណ៍ជំនួយផ្នែកហិរញ្ញវត្ថុដល់និស្សិត
- រៀបចំនិងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតក្រោមការកាន់កាប់និងប្រើប្រាស់របស់សាកលវិទ្យាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. ការិយាល័យធនធានមនុស្ស

- រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យធនធានមនុស្ស
- រៀបចំផែនការធនធានមនុស្សនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- រៀបចំគោលការណ៍អត្ថប្រយោជន៍ផ្សេងៗជូនដល់មន្ត្រីរាជការ សាស្ត្រាចារ្យនិង/ឬគ្រូផ្ទៃក្នុងនិងខាងក្រៅ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីកិច្ចសន្យាផ្ទៃក្នុង
- រៀបចំគោលការណ៍ស្តីពីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីរាជការ សាស្ត្រាចារ្យនិង/ឬគ្រូផ្ទៃក្នុង និងខាងក្រៅ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីកិច្ចសន្យាផ្ទៃក្នុងដែលមានគុណបំណាច់ដល់សាកលវិទ្យាល័យ
- រៀបចំគោលការណ៍ណែនាំស្តីពីការងារស្ម័គ្រចិត្តក្រៅម៉ោងរបស់និស្សិត
- កសាងសមត្ថភាពមន្ត្រីរាជការ សាស្ត្រាចារ្យនិង/ឬគ្រូផ្ទៃក្នុងនិងខាងក្រៅ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីកិច្ចសន្យាផ្ទៃក្នុងប្រចាំឆ្នាំ
- វាយតម្លៃលទ្ធផលនៃការអនុវត្តការងារប្រចាំឆ្នាំរបស់មន្ត្រីរាជការ សាស្ត្រាចារ្យនិង/ឬគ្រូផ្ទៃក្នុងនិងខាងក្រៅ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីកិច្ចសន្យាផ្ទៃក្នុង
- រៀបចំផែនការដំឡើងកាំប្រាក់និងផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ សាស្ត្រាចារ្យនិង/ឬគ្រូផ្ទៃក្នុង

- ជាជំនួយឱ្យក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់សាកលវិទ្យាល័យក្នុងការរៀបចំដំណើរការនៃការផ្តល់ឋានៈជូនដល់គ្រូ/សាស្ត្រាចារ្យ÷ សាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយស្របតាមបទដ្ឋានគតិយុត្ត
- រៀបចំសម្រួលឯកសារសម្រាប់បន្តការសិក្សា លិខិតបំពេញបេសកកម្មក្នុងនិងក្រៅប្រទេសជូនមន្ត្រីរាជការ និងសាស្ត្រាចារ្យនិង/ឬគ្រូ
- សហការជាមួយមហាវិទ្យាល័យនិងអង្គភាពពាក់ព័ន្ធក្នុងដំណើរការជ្រើសរើសមន្ត្រីរាជការសាស្ត្រាចារ្យនិង/ឬគ្រូ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីកិច្ចសន្យាផ្ទៃក្នុង
- ប្រមូលសរុបវត្តមានមន្ត្រីរាជការនិងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ
- រៀបចំនិងផ្តល់យោបល់លើការវាយតម្លៃសម្រាប់ការដំឡើងមុខងារនិងថ្នាក់ដល់មន្ត្រីរាជការរបស់សាកលវិទ្យាល័យ
- រៀបចំបណ្ណសរសើរ ការដាក់ពិន័យ- ស្តីបន្ទោសឬព្រមានដល់មន្ត្រីរាជការ សាស្ត្រាចារ្យនិង/ឬគ្រូ
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៤. ការិយាល័យទំនាក់ទំនងជាតិ- អន្តរជាតិ និង ព័ត៌មាននិងផ្សព្វផ្សាយ

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- ទំនាក់ទំនងជាមួយស្ថាប័នជាតិ- អន្តរជាតិដែលបម្រើឱ្យវិស័យសិល្បៈវប្បធម៌
- ដឹកនាំនិងសហការជាមួយអង្គភាពនានាក្រោមឱវាទសាកលវិទ្យាល័យក្នុងការរៀបចំគម្រោងសំណើដែលឆ្លើយតបទៅនឹងការអភិវឌ្ឍកម្មវិធីសិក្សានិងកិច្ចការស្រាវជ្រាវ
- រៀបចំដំណើរទស្សនកិច្ចសិក្សានិងការផ្លាស់ប្តូរបទពិសោធន៍ជាមួយស្ថាប័នជាតិ- អន្តរជាតិ
- សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការជ្រើសរើសមន្ត្រីរាជការ សាស្ត្រាចារ្យនិង/ឬគ្រូ និងនិស្សិតដើម្បីចូលរួមកម្មវិធីទស្សនកិច្ចសិក្សា ការផ្លាស់ប្តូរបទពិសោធន៍ ការតាំងពិពរណ៍ និងការសម្តែង
- រៀបចំខ្លឹមសារអនុស្សរណៈ កិច្ចព្រមព្រៀង និងកិច្ចសន្យាជាមួយដៃគូជាតិ- អន្តរជាតិ
- សម្របសម្រួលរៀបចំលិខិតអញ្ជើញ លិខិតឆ្លងដែន ទិដ្ឋាការស្នាក់នៅ និងបដិសណ្ឋារកិច្ចភ្ញៀវ សាស្ត្រាចារ្យ និងនិស្សិតអន្តរជាតិដែលទទួលបានអាហារូបករណ៍មកសិក្សា មកទស្សនកិច្ច និងធ្វើការនៅសាកលវិទ្យាល័យ
- រៀបចំបង្កើត គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន÷ គេហទំព័រ សារអេឡិចត្រូនិច បណ្តាញសង្គម ផ្ទាំងផ្សព្វផ្សាយ និងខិតប័ណ្ណផ្សព្វផ្សាយ

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនិងផែនការសកម្មភាពពាក់ព័ន្ធនឹងវិស័យវប្បធម៌និងវិចិត្រសិល្បៈ
- ផលិតព័ត៌មានជាអត្ថបទនិងវីដេអូអំពីមុខជំនាញសិក្សារបស់សាកលវិទ្យាល័យ
- សហការជាមួយអង្គភាពក្រោមឱវាទសាកលវិទ្យាល័យក្នុងការរៀបចំសម្ភារផ្សព្វផ្សាយ និងបោះពុម្ពផ្សាយនូវទស្សនាវដ្ដី ព្រឹត្តិបត្រព័ត៌មាន បណ្ណផ្សព្វផ្សាយព័ត៌មានរបស់សាកលវិទ្យាល័យ
- ផ្តល់ព័ត៌មានរបស់សាកលវិទ្យាល័យជូនអ្នកសារព័ត៌មានជាតិ-អន្តរជាតិដើម្បីជួយផ្សព្វផ្សាយ
- រៀបចំកំណត់ហេតុនៃកិច្ចប្រជុំនិងធ្វើរបាយការណ៍ប្រចាំខែ ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- តាមដានរាល់វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ-អន្តរជាតិ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៣
សិក្សាធិការដ្ឋាន

ប្រការ ៤.-

សិក្សាធិការដ្ឋានមានការិយាល័យក្រោមឱវាទចំនួន៥ដូចខាងក្រោម÷

១. ការិយាល័យសេវានិស្សិត

២. ការិយាល័យកម្មវិធីសិក្សា

៣. ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

៤. ដេប៉ាតឺម៉ង់ភាសា

៥. ការិយាល័យធនធានសិក្សា។

ប្រការ ៥.- តួនាទីភារកិច្ចការិយាល័យនីមួយៗមានដូចតទៅ÷

១. ការិយាល័យសេវានិស្សិត

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- រៀបចំនិងអនុវត្តគោលការណ៍ស្តីពីការចុះឈ្មោះចូលរៀន បន្តការសិក្សា ផ្ទេរការសិក្សា ព្យួរការសិក្សា និងការផ្តល់អាហារូបករណ៍សម្រាប់និស្សិត
- រៀបចំការគ្រប់គ្រងទិន្នន័យនិស្សិត (បញ្ជីឈ្មោះ ប័ណ្ណសម្គាល់ខ្លួន ប្រវត្តិរូប បញ្ជីវត្តមាន ពិន្ទុ) តាមប្រព័ន្ធអេឡិចត្រូនិច
- ពិនិត្យនិងធ្វើបច្ចុប្បន្នភាពបទបញ្ជាផ្ទៃក្នុងឱ្យស្របតាមស្ថានភាពជាក់ស្តែងនៃសាកលវិទ្យាល័យ
- ផ្តល់លិខិតបញ្ជាក់ការសិក្សា ព្រឹត្តិបត្រពិន្ទុ វិញ្ញាបនបត្រ និងសញ្ញាបត្រដល់និស្សិត

- រៀបចំដំណើរការជ្រើសរើសគណៈកម្មការនិស្សិតនិងផ្តល់សេវាប្រឹក្សាទាក់ទងនឹងការសិក្សា
- រៀបចំកម្មវិធីអប់រំនិងប្រឹក្សាយោបល់ផ្នែកសុខភាពដោយមានបន្ទប់បំពាក់នូវឧបករណ៍បរិក្ខារ និងឱសថសម្រាប់សង្គ្រោះបឋម
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យកម្មវិធីសិក្សា

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- ដឹកនាំរៀបចំអភិវឌ្ឍកម្មវិធីសិក្សាដោយសហការជាមួយមហាវិទ្យាល័យជំនាញនិងអង្គភាពពាក់ព័ន្ធឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិងស្របតាមប្រព័ន្ធក្រេឌីត
- ដឹកនាំរៀបចំសៀវភៅគោលមុខវិជ្ជាសិក្សា
- សហការចងក្រងប្លង់គោលមេរៀនតាមសប្តាហ៍និងឆមាសនីមួយៗដោយផ្អែកលើសៀវភៅគោល និងឯកសារយោងផ្សេងៗ
- រៀបចំគោលការណ៍វាយតម្លៃការសិក្សា ការហាត់ការ និងការបញ្ចប់ការសិក្សារបស់និស្សិត
- រៀបចំផែនការសកម្មភាពនិស្សិត ប្រតិទិនសិក្សាប្រចាំឆ្នាំ ចុះកម្មសិក្សា ការចុះហាត់ការ ការប្រឡងឆមាស និងការប្រឡងបញ្ចប់បរិញ្ញាបត្រដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- រៀបចំគ្រប់គ្រងនិងថែទាំប្រព័ន្ធព័ត៌មានវិទ្យា និង ណែនាំវិធីសាស្ត្រប្រើប្រាស់ប្រព័ន្ធវាយតម្លៃ និងដាក់ពិន្ទុនិស្សិត
- សហការរៀបចំបាឋកថា សិក្ខាសាលា សន្និសីទ វគ្គបណ្តុះបណ្តាលផ្សេងៗដើម្បីពង្រីកចំណេះដឹងនិស្សិត និងលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យនិង/ឬគ្រូ
- សំណើជ្រើសរើសសាស្ត្រាចារ្យនិង/ឬគ្រូ ដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងដេប៉ាតឺម៉ង់ភាសាដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- រៀបចំដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងរបស់សាកលវិទ្យាល័យនិងរៀបចំឯកសារដើម្បីវាយតម្លៃទទួលស្គាល់គុណភាពអប់រំពីស្ថាប័នជំនាញ
- រៀបចំយន្តការកំណត់ក្រេឌីត និងគោលការណ៍ផ្ទេរក្រេឌីតគ្រប់កម្រិតតាមបទដ្ឋានគតិយុត្ត
- ពិនិត្យបូកសរុបនិងផ្ទៀងផ្ទាត់ម៉ោងបង្រៀនប្រចាំខែ និងប្រចាំឆ្នាំរបស់គ្រូ/សាស្ត្រាចារ្យតាមមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- ពិនិត្យផ្ទៀងផ្ទាត់លទ្ធផលពិន្ទុប្រចាំឆ្នាំរបស់មហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣.ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- អប់រំ បណ្តុះបណ្តាល និងតម្រង់ទិសនិស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសម្រាប់បន្តការសិក្សាទៅតាមមហាវិទ្យាល័យជំនាញ
- រៀបចំ ដឹកនាំ និងគ្រប់គ្រងទស្សនកិច្ចសិក្សា
- សហការរៀបចំលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យនិង/ ឬគ្រូ
- រៀបចំនិងចងក្រងកម្មវិធីសិក្សា សៀវភៅគោលមេរៀន និងកាលវិភាគសិក្សា
- រៀបចំផែនការជ្រើសរើសសាស្ត្រាចារ្យនិង/ ឬគ្រូ និងសាស្ត្រាចារ្យនិង/ ឬគ្រូបន្តវេន
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៤.ដេប៉ាតឺម៉ង់ភាសា

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ដេប៉ាតឺម៉ង់ភាសា
- រៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សាភាសាបរទេសទូទៅនិងជំនាញ
- សហការ រៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សាជំនាញឯកទេសជាភាសាបរទេស
- រៀបចំនិងអនុវត្តគោលការណ៍ស្តីពីការបង្រៀននិងរៀនភាសាបរទេសតាមជំនាញប្រកបដោយប្រសិទ្ធភាព
- វាយតម្លៃគុណភាពអប់រំភាសាបរទេសដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ផ្សព្វផ្សាយអត្ថប្រយោជន៍ លើកទឹកចិត្តនិស្សិតឱ្យរៀនភាសាបរទេស និងណែនាំតម្រង់ទិសនិស្សិតក្នុងការស្នើសុំអាហារូបករណ៍ទៅបន្តការសិក្សានៅបរទេស
- ចូលរួមសហការសរសេរគម្រោងស្នើសុំថវិកានិងអនុវត្តគម្រោងស្រាវជ្រាវនានា
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៥.ការិយាល័យធនធានសិក្សា

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- កៀរគរការគាំទ្របច្ចេកទេសនិងថវិកាប្រចាំឆ្នាំ
- រៀបចំគោលការណ៍ស្ដីពីលទ្ធផលសិក្សានិងអត្រាបញ្ចប់ការសិក្សា
- រៀបចំ ចងក្រងបញ្ជីឯកសារយោង និងបោះពុម្ពសៀវភៅគោលសម្រាប់មុខវិជ្ជាមួយចំនួនដែលផ្ដត់ផ្គង់ដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតតាមរយៈសៀវភៅនិងអេឡិចត្រូនិច
- គ្រប់គ្រង បែងចែក ថែទាំបន្ទប់សិក្សា និងផ្គត់ផ្គង់សម្ភារបង្រៀន និងរៀនទាំងព័ត៌មានវិទ្យា និងមិនមែនព័ត៌មានវិទ្យា
- សិក្សា វិភាគ វាយតម្លៃមុខវិជ្ជាសិក្សា និងចងក្រងរាល់ខ្លឹមសារដែលជាចំណុចគោលទៅតាមជំនាញនានាដោយសហការជាមួយមហាវិទ្យាល័យ អង្គភាពពាក់ព័ន្ធ និងវិស័យឯកជន
- រៀបចំនិងធ្វើរបាយការណ៍នៃការស្ទង់មតិចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សា
- រៀបចំនិងកសាងបណ្ដាញអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ
- គ្រប់គ្រងបញ្ជីសារពើភណ្ឌរបស់សិក្សាធិការដ្ឋាន
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៤

មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌និងនវានុវត្តន៍

ប្រការ ៦.-

មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌និងនវានុវត្តន៍មានការិយាល័យក្រោមឱវាទចំនួន៣ដូចខាងក្រោម÷

១.ការិយាល័យស្រាវជ្រាវវប្បធម៌

២.ការិយាល័យពិសោធន៍និងនវានុវត្តន៍

៣.បណ្ណាល័យ។

ប្រការ ៧.- តួនាទីភារកិច្ចការិយាល័យនីមួយៗមានដូចតទៅ÷

១.ការិយាល័យស្រាវជ្រាវវប្បធម៌

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- ដឹកនាំនិងសរសេរគម្រោងស្រាវជ្រាវរយៈពេលខ្លី មធ្យម និងវែង
- រៀបចំក្រុមអ្នកស្រាវជ្រាវទៅតាមជំនាញ/ផ្នែក ដើម្បីធ្វើការប្រមូលទិន្នន័យ វិភាគ វាយតម្លៃ និង

lui ...

ផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវ

- រៀបចំសិក្ខាសាលាបង្ហាញពីលទ្ធផលស្រាវជ្រាវ ប្រមូលធាតុចូលបំពេញបន្ថែម
- ពិនិត្យកែសម្រួល ចងក្រងលទ្ធផលនៃការងារស្រាវជ្រាវនិងបោះពុម្ពផ្សាយ
- ស្វែងរកដៃគូសហប្រតិបត្តិការដើម្បីពង្រីកធនធានហិរញ្ញវត្ថុ ការគាំទ្រផ្នែកបច្ចេកទេស និងកិច្ចការសិក្សាស្រាវជ្រាវកម្រិតជាតិ-អន្តរជាតិ
- ផ្តល់ការប្រឹក្សា វិធីសាស្ត្រស្រាវជ្រាវ ប្រភពឯកសារ និងបច្ចេកទេសផ្សេងៗដល់និស្សិត សាស្ត្រាចារ្យនិង/ឬគ្រូ និងអ្នកស្រាវជ្រាវទូទៅ
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យពិសោធន៍និងនវានុវត្តន៍

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ការិយាល័យ
- ដឹកនាំកិច្ចការពិសោធន៍ វិភាគ និងនវានុវត្តន៍ស្នាដៃសិល្បៈវប្បធម៌
- គ្រប់គ្រងនិងថែទាំមន្ទីរពិសោធន៍-រោងជាង ផ្គត់ផ្គង់សម្ភារបរិក្ខារនវានុវត្តន៍ និងបច្ចេកវិទ្យាតាមជំនាញ
- រៀបចំពិព័រណ៍និងសាជីវកម្មដើម្បីផ្សព្វផ្សាយសមិទ្ធផល និងលើកកម្ពស់ស្នាដៃសិល្បៈវប្បធម៌
- សហការជាមួយស្ថាប័នពាក់ព័ន្ធនានាដើម្បីស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស
- គ្រប់គ្រងបញ្ជីសារពើភណ្ឌរបស់មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌និងនវានុវត្តន៍
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. បណ្ណាល័យ

- រៀបចំផែនការសកម្មភាពនិងថវិការយៈពេលខ្លី មធ្យម និងវែងរបស់បណ្ណាល័យ
- រៀបចំនិងគ្រប់គ្រងបញ្ជីឯកសារតាមប្រព័ន្ធបច្ចេកវិទ្យា
- រៀបចំធ្វើបច្ចុប្បន្នភាពឯកសារនិងបំប្លែងទៅជាឯកសារអេឡិចត្រូនិច
- ផ្តល់ព័ត៌មាននិងសេវាប្រើប្រាស់បណ្ណាល័យ
- ជួសជុលនិងថែទាំឯកសារ
- រៀបចំបរិស្ថានបណ្ណាល័យប្រកបដោយផាសុកភាព
- សហការជាមួយស្ថាប័នពាក់ព័ន្ធនានាដើម្បីស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ ឯកសារ និងបច្ចេកទេស

- ផ្គត់ផ្គង់ឯកសារថ្មីៗដែលពាក់ព័ន្ធនឹងជំនាញរបស់សាកលវិទ្យាល័យ
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំរបស់ការិយាល័យ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៥
អង្គភាពលទ្ធកម្ម

ប្រការ ៨.-

អង្គភាពលទ្ធកម្ម មានរចនាសម្ព័ន្ធស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីសាកលវិទ្យាធិការនិងជាលេខាធិការដ្ឋានឱ្យគណៈកម្មាធិការលទ្ធកម្ម។

ប្រការ ៩.-

អង្គភាពលទ្ធកម្មទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៣ អនក្រ.បក. ចុះថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្មនិងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៦
អង្គភាពសវនកម្មផ្ទៃក្នុង

ប្រការ ១០.-

អង្គភាពសវនកម្មផ្ទៃក្នុងរបស់សាកលវិទ្យាល័យ ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងវាយតម្លៃសកម្មភាពរបស់អង្គភាពដើម្បីជាជំនួយសម្រាប់ថ្នាក់ដឹកនាំនិងក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យ។

ប្រការ ១១.-

អង្គភាពសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក. ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ននិងសហគ្រាសសាធារណៈ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៧
ការតែងតាំងនិងបញ្ចប់ពីមុខតំណែង

ប្រការ ១២.-

ប្រធាននិងអនុប្រធានការិយាល័យ-អង្គភាពនានា ត្រូវបានតែងតាំងនិងបញ្ចប់ពីមុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈតាមសំណើរបស់សាកលវិទ្យាធិការដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។

ជំពូកទី៨
អវសានប្បញ្ញត្តិ

ប្រការ ១៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ១៤.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរា អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងប្រធានអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំខាលចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី